**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

អនុក្រឹត្យនេះ មានគោលបំណងដាក់ចេញនូវវិធានការលើកទឹកចិត្តផ្នែកពន្ធដាររបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមចំណែកអភិវឌ្ឍសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម តាមរយៈការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត។

**មាត្រា ២.- គោលដៅ**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវយន្តការលើកទឹកចិត្តផ្នែកពន្ធដារដល់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យមដែលពុំទាន់បានចុះបញ្ជីពន្ធដារ ឱ្យស្ម័គ្រចិត្តមកចុះបញ្ជីបំពេញកាតព្វកិច្ចសារពើពន្ធ ដើម្បីបង្កើតបរិយាកាសបង់ពន្ធ ប្រកបដោយតម្លាភាពនិងសមធម៌។

**មាត្រា ៣.- វិសាលភាព**

ការលើកទឹកចិត្តផ្នែកពន្ធដារដូចមានចែងក្នុងអនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះតែសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងអំឡុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ប៉ុណ្ណោះ។

**មាត្រា ៤.- និយមន័យ**

សម្រាប់គោលដៅនៃអនុក្រឹត្យនេះ÷

១- ពាក្យ "សហគ្រាសធុនតូច" សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ៧០០ លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូចស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

២- ពាក្យ "សហគ្រាសធុនមធ្យម" សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០ លានរៀល ដល់ ២ ០០០ លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យមស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។



www.pheakdeylaw.com

## ជំពូកទី ២
## ការលើកទឹកចិត្តផ្នែកពន្ធដារ និងកាតព្វកិច្ចសារពើពន្ធ

**មាត្រា ៥.- ការលើកទឹកចិត្តផ្នែកពន្ធដារ**

១- សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងអំឡុងឆ្នាំ ២០១៧ និងឆ្នាំ២០១៨ ត្រូវបានលើកលែងពន្ធលើប្រាក់ចំណូលចំនួន ២ ឆ្នាំ ដោយគិតចាប់ពីឆ្នាំដែលទទួលបានប្រាក់ចំណូលដំបូងចំពោះសហគ្រាសដែលពុំទាន់មានប្រាក់ចំណូល ឬចាប់ពីឆ្នាំដែលចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមានប្រាក់ចំណូលរួចហើយ។ ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលនេះ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យមត្រូវបានលើកលែងពីការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា។

២- ផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ត្រូវបង់ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមាទៅតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីសារពើពន្ធ។

៣- ការលើកលែងពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ មិនអនុវត្តចំពោះសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលមិនបានមកចុះបញ្ជីដោយស្ម័គ្រចិត្តទេ។

**មាត្រា ៦.- កាតព្វកិច្ចសារពើពន្ធ**

សហគ្រាសដែលបានចុះបញ្ជីជាអ្នកជាប់ពន្ធតូច និងសហគ្រាសដែលបានចុះបញ្ជីជាអ្នកជាប់ពន្ធមធ្យម ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅតាមកាលកំណត់ជូនរដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវបានលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះក្តី និងត្រូវដាក់លិខិតប្រកាសបង់ពន្ធអាករដទៃទៀតតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

**មាត្រា ៧.- ការខកខានមិនបានចុះបញ្ជី**

សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលខកខានមិនបានចុះបញ្ជីពន្ធដារ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះនិងត្រូវអនុវត្តដោយម៉ឺងម៉ាត់តាមបទប្បញ្ញត្តិ នៃមាត្រា១២៨ ដល់មាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។

**មាត្រា ៨.- ការណែនាំអនុវត្តអនុក្រឹត្យ**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសណែនាំអំពីវិធាននិងនីតិវិធីនៃការអនុវត្តអនុក្រឹត្យនេះ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៩.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។



www.pheakdeylaw.com

**មាត្រា ១០.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com